# របាយការណ៍សង្ខេបស្តីពីការវាយតម្លៃបឋមលើផលប៉ះពាល់នៃ
# សេចក្តីព្រាងប្រកាស
# ស្តីពី
# "នីតិវិធីនិងលក្ខខណ្ឌក្នុងការផ្តល់អាជ្ញាបណ្ណធនធានរ៉ែ សម្រាប់ការធ្វើអាជីវកម្មបូមខ្សាច់ទន្លេ ស្ទឹង ព្រែក និងបឹងបួរ លក្ខណៈសិប្បកម្ម និងទ្រង់ទ្រាយតូច"

រហូតមកដល់បច្ចុប្បន្ន ក្រសួងរ៉ែនិងថាមពលបានដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តជាច្រើន សម្រាប់ធ្វើការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានរ៉ែដើម្បីលើកស្ទួយសេដ្ឋកិច្ចប្រទេសជាតិ ដែលក្នុងនោះក៏បានចែងអំពីលក្ខខណ្ឌតម្រូវជាច្រើនក្នុងការផ្តល់អាជ្ញាបណ្ណធនធានរ៉ែ ជាពិសេស អាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែសម្រាប់ការបូមយកខ្សាច់ ដី ល្បាប់ ឬក្រួសតាមផ្លូវទឹក។

សំណើបញ្ញត្តិកម្មជាសេចក្តីព្រាងប្រកាសស្តីពី "នីតិវិធីនិងលក្ខខណ្ឌក្នុងការផ្តល់អាជ្ញាបណ្ណធនធានរ៉ែសម្រាប់ការធ្វើអាជីវកម្មបូមខ្សាច់ទន្លេ ស្ទឹង ព្រែក និងបឹងបួរលក្ខណៈសិប្បកម្ម និងទ្រង់ទ្រាយតូច" នេះបានធ្វើឡើងស្របតាមជំពូកទី៤ នៃច្បាប់ស្តីពី "ការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ" ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងក្នុងការគ្រប់គ្រងអាជីវកម្មសិប្បកម្មធនធានរ៉ែ បង្កើនចំណូលរដ្ឋ និងកាត់បន្ថយការធ្វើប្រតិបត្តិការបូមយកខ្សាច់ដោយខុសច្បាប់ គ្មានបច្ចេកទេស និងមិនគោរពតាមលក្ខខណ្ឌនៃអាជ្ញាបណ្ណ ដើម្បីចូលរួមកាត់បន្ថយផលប៉ះពាល់ដល់បរិស្ថាន សង្គម និងធនធានធម្មជាតិ និងបង្កើតឱ្យមានប្រសិទ្ធិភាព គណនេយ្យភាព និងតម្លាភាពក្នុងការធ្វើអាជីវកម្មបូមខ្សាច់ខ្នាតតូចតាមទន្លេ ស្ទឹង ព្រែក និងបឹងបួរ។

ដើម្បីធានាឱ្យបាននូវមូលដ្ឋាននៃការសិក្សា វិភាគ និងប្រៀបធៀបដែលមានប្រសិទ្ធភាពខ្ពស់ ក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តបានសម្រេចជ្រើសយកជម្រើសចំនួនពីរដើម្បីយកមកធ្វើការពិភាក្សា ដែលមានខ្លឹមសារដូចខាងក្រោម៖

- ជម្រើសទី១៖ រក្សាស្ថានភាពដើមនិងពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់។
- ជម្រើសទី២៖ ចេញសេចក្តីព្រាងប្រកាស ស្តីពី នីតិវិធី និងលក្ខខណ្ឌក្នុងការផ្តល់អាជ្ញាបណ្ណធនធាន រ៉ែ សម្រាប់ការធ្វើអាជីវកម្មបូមខ្សាច់ទន្លេ ស្ទឹង ព្រែក និងបឹងបួរ លក្ខណៈសិប្បកម្មនិងទ្រង់ទ្រាយតូច។

យោងតាមលទ្ធផលដែលទទួលបានមកពីការវិភាគបន្ទុកចំណាយ និងផលចំណេញនៃជម្រើសទាំងពីរ យើងបានរកឃើញថាការចំណាយរបស់រាជរដ្ឋាភិបាលក្នុងជម្រើសទី១មានចំនួន **៧០ ៤៣៨,៩១** (ចិតសិបពាន់ បួនរយសាមសិបប្រាំបី និងកៅសិបមួយសេន) ដុល្លារអាមេរិក ហើយការចំណាយរបស់ធុរកិច្ចក្នុងជម្រើសទី១មានចំនួន **១៣ ៦៥០** (ដប់បីពាន់ ប្រាំមួយរយហាសិប)

ដុល្លារសហរដ្ឋអាមេរិកគត់។ ចំពោះជម្រើសទី២ការចំណាយរបស់រាជរដ្ឋាភិបាលមានចំនួន **៧៦ ៨៨១,៧៤** (ចិតសិបប្រាំមួយពាន់ ប្រាំបីរយប៉ែតសិបមួយ និងចិតសិបបួន) ដុល្លារអាមេរិក ហើយការចំណាយរបស់ធុរកិច្ចក្នុងជម្រើសទី២មានចំនួន **១៥ ២២៥** (ដប់ប្រាំពាន់ ពីរយម្ភៃប្រាំ) ដុល្លារអាមេរិកគត់។

ផ្អែកលើលទ្ធផលនៃការវិភាគលើបន្ទុកចំណាយនិងផលចំណេញនៃជម្រើសទាំងពីរខាងលើ យើងគួជ្រើសរើសយកជម្រើសទី១ដោយសារមូលហេតុដូចខាងក្រោម៖

១- ទាំងចំណាយរបស់រាជរដ្ឋាភិបាលនិងចំណាយធុរកិច្ចរបស់ជម្រើសទី១ មានចំនួនតិចជាងចំណាយរបស់រាជរដ្ឋាភិបាលនិងចំណាយធុរកិច្ចរបស់ជម្រើសទី២

២- ខ្លឹមសារនៃលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់ ពិសេសខ្លឹមសារនៃប្រកាសលេខ ៣២១រថ.អធរ.ប្រក ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៧ ស្ដីពី "ការធ្វើប្រតិភូកម្មមុខងារក្នុងការផ្ដល់អាជ្ញាបណ្ណធនធានរ៉ែសម្រាប់ប្រតិបត្តិការរ៉ែមានលក្ខណៈជាសិប្បកម្ម និងខ្នាតតូចទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិរាជធានី ខេត្ត" មានអត្ថន័យគ្រប់គ្រាន់ និងបានបញ្ជាក់ច្បាស់អំពីនីតិវិធីក្នុងការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណពាក់ព័ន្ធនានា។

៣- ខ្លឹមសារនៃសេចក្ដីព្រាងប្រកាសស្ដីពី "នីតិវិធីនិងលក្ខខណ្ឌក្នុងការផ្ដល់អាជ្ញាបណ្ណធនធានរ៉ែសម្រាប់ការធ្វើអាជីវកម្មបូមខ្សាច់ទន្លេ ស្ទឹង ព្រែក និងបឹងបួរលក្ខណៈសិប្បកម្ម និងទ្រង់ទ្រាយតូច" មានភាពស្មុគស្មាញ និងអាចធ្វើឱ្យអាជីវករមានការភាន់ច្រឡំថែមទៀតផង។

ដោយសារខ្លឹមសារនៃលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់បានកំណត់អំពីបច្ចេកទេសក្នុងការធ្វើប្រតិបត្តិការធនធានរ៉ែគ្រប់គ្រាន់ហើយនោះ ក្រសួងរ៉ែនិងថាមពលគួរបន្តពង្រឹងសមត្ថភាពក្រុមការងារអធិការកិច្ចរបស់ក្រសួងនិងធ្វើការផ្សព្វផ្សាយអំពីខ្លឹមសារទាំងនោះទៅឱ្យសាធារណៈជន ពិសេសអាជីវករធនធានរ៉ែឱ្យបានយល់ដឹងកាន់តែច្បាស់បន្ថែមទៀត។ ជាមួយគ្នានេះផងដែរ ក្រសួងរ៉ែនិងថាមពលត្រូវបន្តពង្រឹងសមត្ថភាពមន្ត្រី និងបន្តការលើកកម្ពស់ប្រសិទ្ធិភាពក្នុងការតាមដានពិនិត្យ និងការធ្វើអធិការកិច្ចលើលក្ខខណ្ឌបច្ចេកទេសនៃប្រតិបត្តិការបូមយកខ្សាច់ទន្លេ ស្ទឹង ព្រែក និងបឹងបួរលក្ខណៈសិប្បកម្មនិងទ្រង់ទ្រាយតូច ដើម្បីធានាឱ្យបាននូវប្រសិទ្ធិភាព គណនេយ្យភាព និងតម្លាភាពក្នុងការគ្រប់គ្រងអាជីវកម្មធនធានរ៉ែខ្សាច់។

# ការវាយតម្លៃបឋមលើផលប៉ះពាល់

| | | |
|---|---|---|
| បញ្ញត្តិកម្ម | ៖ | សេចក្តីព្រាងប្រកាសស្តីពីនិតិវិធី និងលក្ខខណ្ឌក្នុងការផ្តល់អាជ្ញាបណ្ណធនធានរ៉ែ សម្រាប់ការធ្វើអាជីវកម្មបូមខ្សាច់ទន្លេ ស្ទឹង ព្រែក និងបឹងបួរលក្ខណៈ សិប្បកម្ម និងទ្រង់ទ្រាយតូច |
| ក្រសួង/ស្ថាប័ន | ៖ | ក្រសួងរ៉ែនិងថាមពល |
| លេខយោង | ៖ | ០០០៧/រថ |
| កាលបរិច្ឆេទចាប់ផ្តើម | ៖ | ថ្ងៃទី០១ ខែ មេសា ឆ្នាំ២០១៦ |
| កាលបរិច្ឆេទបញ្ចប់ | ៖ | ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៨ |

## អត្ថាធិប្បាយសង្ខេបអំពីសំណើបញ្ញត្តិកម្ម

**ប្រកាសនេះមានគោលបំណង**

កំណត់នូវនីតិវិធី លក្ខខណ្ឌ និងគោលការណ៍ជាក់លាក់ក្នុងការផ្តល់អាជ្ញាបណ្ណធនធានរ៉ែ ដោយមន្ទីររ៉ែ និងថាមពលរាជធានី ខេត្ត សម្រាប់កាធ្វើអាជីវកម្មបូមខ្សាច់ទន្លេ ស្ទឹង ព្រែក និង បឹងបួរដែលមានលក្ខណៈសិប្បកម្មនិងទ្រង់ទ្រាយតូច។

បង្កើតឱ្យមានប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព ក្នុងការគ្រប់គ្រងអាជីវកម្មធនធានរ៉ែខ្សាច់ កាត់បន្ថយជាអតិបរមានូវផលប៉ះពាល់បរិស្ថាននិងសង្គម លើកកម្ពស់ចំណូលជាតិពីវិស័យធនធានរ៉ែ និង ដើម្បីជាមូលដ្ឋានបច្ចេកទេសសម្រាប់មន្ទីររ៉ែនិងថាមពលយកទៅអនុវត្តការងាររបស់ខ្លួន។

**វិសាលភាព**

ប្រកាសនេះមានវិសាលភាពគ្របដណ្តប់ លើរាល់សកម្មភាពអាជីវកម្មបូមខ្សាច់ទន្លេ ស្ទឹង ព្រែក និង បឹងបួរ ក្នុងលក្ខណៈសិប្បកម្ម ឬទ្រង់ទ្រាយតូច។

**កាតព្វកិច្ចចំពោះធុរកិច្ច**

- អាជ្ញាបណ្ណខាងលើនេះអាចផ្តល់ឲ្យចំពោះតែអាជីវកម្មដែលមានទំហំផ្ទៃការដ្ឋានមិនលើសពី១ហិកតា និងក្នុងជម្រៅអាជីវកម្មដែលប្រើប្រាស់ម៉ាស៊ីនបូមមានកម្លាំងសរុបមិនលើសពី៧៥សេះ ជម្រៅមិនត្រូវលើសពី០១ម៉ែត្រពីលើកម្រិតជម្រៅជ្រៅបំផុតនៃបាតទន្លេ ស្ទឹង ឬបឹងបួរ ឬ ក្នុងលក្ខខណ្ឌជម្រៅកំណត់ដោយក្រសួងរ៉ែនិងថាមពល
- សកម្មភាពអាជីវកម្មអនុវត្តត្រឹមត្រូវតាមស្តង់ដាបទដ្ឋានការពារបរិស្ថាននិងសង្គមដែលកំណត់ដោយក្រសួងបរិស្ថាន
- អនុវត្តតាមលក្ខខណ្ឌតម្រូវផ្សេងទៀតដូចមានចែងក្នុងប្រកាសលេខ ០០០២ រថ.អធរ.ប្រក ចុះថ្ងៃទី ០៨ ខែមករា ឆ្នាំ២០១៥ និងប្រកាសលេខ៥២០ រថ.រស.ប្រក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤
- ទីតាំងប្រតិបត្តិការបូមខ្សាច់និងទីតាំងដេប៉ូស្តុកខ្សាច់ត្រូវស្ថិតនៅក្នុងចម្ងាយមានសុវត្ថិភាពពីច្រាំងទន្លេស្របតាមលក្ខណៈបច្ចេកទេស

- ទីតាំងដេប៉ូស្តុកខ្សាច់ត្រូវមានទំនប់ព័ទ្ធជុំវិញគំនរខ្សាច់ និងរៀបចំដាក់បំពង់សម្រាប់បង្ហូរទឹកចេញឱ្យបានត្រឹមត្រូវ
- អាជីវករដែលមានអាជ្ញាបណ្ណបូមខ្សាច់ស្ទឹង ទន្លេ ព្រែក និងបឹងបួរជាលក្ខណៈសិប្បកម្ម ឬទ្រង់ទ្រាយតូចទាំងអស់មានការតព្វកិច្ចត្រូវបង់ថ្លៃអាជ្ញាបណ្ណ ថ្លៃឈ្នួលដី សួយសារ និងកាតព្វកិច្ចសារពើពន្ធ និងមិនមែនសារពើពន្ធទាំងអស់ផ្សេងទៀតស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន
- អាជីវករត្រូវធ្វើការពិគ្រោះយោបល់ និងស្នើសុំការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធស្របតាមការតម្រូវនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា និងធ្វើការពិគ្រោះយោបល់ជាមួយ សហគមន៍ដែលប៉ះពាល់ក្នុងដំណើរការប្រតិបត្តិការអាជីវកម្មរបស់ខ្លួន។

**កាតព្វកិច្ចចំពោះមន្ទីររ៉ែនិងថាមពល**

- ត្រូវរៀបចំកំណត់ហេតុកិច្ចព្រមព្រៀងបន្ថែមជាមួយអាជីវករ អំពីកាតព្វកិច្ចហិរញ្ញវត្ថុបន្ថែមដូចជា៖
  - មូលនិធិរ៉ែសម្រាប់ទ្រទ្រង់កិច្ចអភិវឌ្ឍសហគមន៍មូលដ្ឋាន
  - ថវិកាគ្រប់គ្រងនិងបណ្តុះបណ្តាលក្នុងវិស័យធនធានរ៉ែ និងបន្ថែមចំណូលជាតិ
  - ក្រសួងរ៉ែនិងថាមពលនិងស្ថាប័នក្រោមឱវាទអាចព្យួរឬបញ្ចប់អាជ្ញាបណ្ណរបស់អាជីវករបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរ

- ការព្យួរឬបញ្ចប់អាជ្ញាបណ្ណអាចធ្វើឡើងក្នុងករណីដែល៖
  - អាជីវករដែលជាម្ចាស់អាជ្ញាបណ្ណធនធានរ៉ែបានល្មើសនិងច្បាស់ជាធរមាន ខកខានក្នុងការអនុវត្តតាមបទប្បញ្ញត្តិណាមួយនៃប្រកាសនេះ ឬមិនគោរពតាមបទបញ្ជាដែលចេញដោយក្រសួងរ៉ែនិងថាមពល
  - អាជីវករខកខានក្នុងការអនុវត្តតាមកាតព្វកិច្ចក្នុងអំឡុងពេល៦០ថ្ងៃបន្ទាប់ពីបានទទួលបានសេចក្តីជូនដំណឹងរបស់ក្រសួងរ៉ែនិងថាមពល អាជីវករដែលក្លាយជាអ្នកជំពាក់បំណុល ក្ស័យធន ឬត្រូវរំលាយក្រុមហ៊ុន
  - ក្រសួងពិនិត្យឃើញថាប្រតិបត្តិការធនធានរ៉ែក្រោមអាជ្ញាបណ្ណធនធានរ៉ែត្រូវបាន អនុញ្ញាត្តិក្នុងតំបន់ដែលពុំទាន់មានការកំណត់កម្រិតហានិភ័យដល់បរិស្ថាននិងសង្គម
  - ក្នុងករណីចាំបាច់មន្ទីរត្រូវរៀបចំកិច្ចពិគ្រោះយោបល់និងវេទិការជាសាធារណៈ

- ក្រោយពេលចេញអាជ្ញាបណ្ណជូនអាជីវកររួច មន្ទីររ៉ែនិងថាមពលត្រូវធ្វើការត្រួតពិនិត្យជាប្រចាំនូវលក្ខណៈបច្ចេកទេសនៃប្រតិបត្តិការរបស់អាជីវករ និងភាពអនុលោមនៃប្រកាសនេះ ហើយត្រូវរាយការណ៍ជាប្រចាំមកក្រសួងរ៉ែនិងថាមពលនូវវឌ្ឍនភាពរបស់សម្បទានិកដែលធ្វើប្រតិបត្តិការអាជីវកម្មខ្សាច់ទាំងអស់ ដោយភ្ជាប់មកនូវរបាយការណ៍ប្រចាំខែផង។

## ប្រភេទបញ្ញត្តិកម្ម៖

| ច្បាប់ | ព្រះរាជក្រឹត្យ | អនុក្រឹត្យ | ប្រកាស | សេចក្តីសម្រេច | សារាចរ | ផ្សេងៗទៀត |
|---|---|---|---|---|---|---|
| ☐ | ☐ | ☐ | ☑ | ☐ | ☐ | ☐ |

**ផលប៉ះពាល់ចម្បងនៃសំណើបញ្ញត្តិកម្មលើវិស័យ៖**

☐ សេដ្ឋកិច្ច ☐ សង្គមកិច្ច ☑ បរិស្ថាន ☐ ផ្សេងៗ..........

## ១. ការកំណត់បញ្ហា

### ១.១. បញ្ហាចម្បងដែលបញ្ញត្តិកម្មនេះមានបំណងដោះស្រាយ

**-ការបំពុលបរិស្ថាននិងធនធានធម្មជាតិ**

ការធ្វើអាជីវកម្មបូមខ្សាច់ខុសច្បាប់ដែលពុំមានបទដ្ឋានបច្ចេកទេសត្រឹមត្រូវនិងគ្រប់គ្រាន់នាំឱ្យមានការបាក់ច្រាំងឬការប្រែប្រួលស្ថានភាពដីនៅតំបន់ប្រតិបត្តិការធនធានរ៉ែ ដែលបណ្តាលឱ្យប៉ះពាល់ដល់លំនៅដ្ឋានរបស់ប្រជាពលរដ្ឋក្នុងតំបន់ បង្កមានគ្រោះថ្នាក់ដល់ជីវិតមនុស្សសត្វ និងប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន និងធនធានធម្មជាតិតាមរយៈការបំពុលទឹកដែលប៉ះពាល់ដល់មច្ឆានិងជីវៈចំរុះនៅតាមទន្លេ ស្ទឹង ព្រែក និងបឹងបួរ។

**-ការបាត់បង់ចំណូលរដ្ឋ**

ការធ្វើអាជីវកម្មធនធានរ៉ែអណាធិបតេយ្យ និងខុសច្បាប់ដែលគ្មានអាជ្ញាបណ្ណត្រឹមត្រូវនាំឱ្យមានផលប៉ះពាល់សេដ្ឋកិច្ចប្រទេសជាតិដូចជា ការបាត់បង់ចំណូលរដ្ឋតាមរយៈការប្រមូលសួយសារ ពន្ធអាករ ឬថ្លៃដាក់ពាក្យសុំអាជ្ញាបណ្ណ ។ល។

### ១.២.បញ្ហាពាក់ព័ន្ធផ្សេងៗទៀតដែលបញ្ញត្តិកម្មនេះអាចជួយដោះស្រាយបានផងដែរ

-ភាពស្មុគស្មាញនិងពិបាកក្នុងការគ្រប់គ្រងប្រតិបត្តិការធនធានរ៉ែឱ្យត្រូវតាមស្តង់ដាបច្ចេកទេសពិសេស ដោយសារការមិនអនុវត្តតាមច្បាប់និងបទប្បញ្ញត្តជាធរមាននានាឱ្យបានត្រឹមត្រូវ។

-ប្រព័ន្ធធារាសាស្រ្តមានការកកស្ទះ ដោយសារមានខ្សាច់ដុះនៅតាមប្រភពទឹកដែលនាំឱ្យមានការពិបាកក្នុងធ្វើចរាចរណ៍តាមផ្លូវទឹក

-ប្រជាកសិករនៅតំបន់មួយចំនួនជួបប្រទះបញ្ហានៃការខ្វះខាតទឹកប្រើប្រាស់សម្រាប់ធ្វើដំណាំ ស្រែចំការ ដោយសារការដុះខ្សាច់។

### ១.៣. បញ្ជីលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់ ដែលពាក់ព័ន្ធឬប្រហាក់ ប្រហែល

១. ច្បាប់ស្តីពី ការគ្រប់គ្រងនិង ធ្វើអាជីវកម្មធនធានរ៉ែ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៧/០៩ ចុះថ្ងៃទី១៣ ខែ កក្កដា ឆ្នាំ ២០០១។ លិខិតបទដ្ឋានគតិយុត្តនេះមានវិសាលភាពធំទូលាយ និងមិនបានកំណត់នូវនីតិវិធីនិងលក្ខខណ្ឌជាក់លាក់ដើម្បីយកមកប្រើប្រាស់ក្នុងគ្រប់គ្រងនិងផ្តល់អាជ្ញាបណ្ណធនធានរ៉ែសម្រាប់ការធ្វើអាជីវកម្មបូមខ្សាច់ទន្លេ ស្ទឹង ព្រែក និងបឹងបួរលក្ខណៈសិប្បកម្មនិងទ្រង់ទ្រាយតូចនេះទេ។

២. ប្រកាសលេខ ៣២១រថ.អធរ.ប្រក ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពី "ការធ្វើប្រតិភូកម្មមុខងារក្នុងការផ្តល់អាជ្ញាបណ្ណធនធានរ៉ែសម្រាប់ប្រតិបត្តិការរ៉ែមានលក្ខណៈជាសិប្បកម្មនិងខ្នាតតូចទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិរាជធានី ខេត្ត។ ប្រកាសនេះមានគោលបំណងលើកកម្ពស់គុណភាព ប្រសិទ្ធភាពតម្លាភាព និងគណនេយ្យភាពនៃការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ តាមរយៈការធ្វើប្រតិភូកម្មមុខ

ងារក្នុងការផ្តល់សេវារដ្ឋបាលពាក់ព័ន្ធនឹងការផ្តល់អាជ្ញាបណ្ណធនធានរ៉ែសម្រាប់ប្រតិបត្តិការរ៉ែមានលក្ខណៈជាសិប្បកម្មនិងខ្នាតតូចទៅឱ្យរដ្ឋបាលរាជធានី ខេត្ត។ ប្រកាសនេះបានកំណត់ច្បាស់លាស់អំពីគោលការណ៍ នីតិវិធី បែបបទ និងលក្ខខណ្ឌក្នុងការផ្តល់និងចុះបញ្ជីអាជ្ញាបណ្ណធនធានរ៉ែចំនួនប្រាំពីរប្រភេទ ដែលក្នុងនោះក៏បានរាប់បញ្ចូលផងដែរនូវអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែសម្រាប់ការបូមយកខ្សាច់ ដី ល្បាប់ ឬក្រួសតាមផ្លូវទឹកផងដែរ។

(សេចក្តីព្រាងប្រកាស)

## ២. គោលបំណង

ប្រកាសនេះមានគោលបំណង ៖

- កាត់បន្ថយការធ្វើអាជីវកម្មដោយខុសច្បាប់ គ្មានបច្ចេកទេស និងមិនគោរពតាមលក្ខខណ្ឌអាជ្ញាបណ្ណ
- កាត់បន្ថយផលប៉ះពាល់ដល់បរិស្ថាន សង្គម និងធនធានធម្មជាតិ
- បង្កើតឲ្យមានប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាពក្នុងការធ្វើអាជីវកម្មបូមខ្សាច់ទន្លេ ស្ទឹង ព្រែក និងបឹងបួរ
- ធ្វើឲ្យប្រសើរឡើងក្នុងការគ្រប់គងអាជីវកម្ម និងបង្កើនចំណូលរដ្ឋ

## ៣. ជម្រើស

ជម្រើសទី១៖ រក្សាស្ថានភាពដើមនិងពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់។

ជម្រើសទី២៖ ចេញសេចក្តីព្រាងប្រកាស ស្តីពី នីតិវិធី និងលក្ខខណ្ឌក្នុងការផ្តល់អាជ្ញាបណ្ណធនធាន រ៉ែ សម្រាប់ការធ្វើអាជីវកម្មបូមខ្សាច់ទន្លេ ស្ទឹង ព្រែក និងបឹងបួរ លក្ខណៈសិប្បកម្មនិងទ្រង់ទ្រាយតូច។

## ៤. ការប៉ាន់ស្មានបឋមលើប្រភេទបន្ទុកចំណាយភាគពាកិច្ច និងផលចំណេញ

### ៤.១. ការកំណត់ភារកិច្ច និងប្រភេទបន្ទុកចំណាយ

| ជម្រើស | រាជរដ្ឋាភិបាល | ធុរកិច្ច |
|---|---|---|
| ជម្រើសទី១៖ រក្សាស្ថានភាពដើម និងពង្រឹងការអនុវត្តលិខិតបទដ្ឋានដែលមានស្រាប់ | **ចំណាយសរុប 70 438,91 USD**<br>- សិក្ខាសាលាផ្សព្វផ្សាយសាធាណៈ ចំនួន ៣ លើក<br>- ក្រុមការងារអធិការកិច្ច<br>- ចំណាយរដ្ឋបាលផ្សេងៗ 2% | **ចំណាយសរុបចំនួន 13 650 USD**<br>- ម៉ាស៊ីនខ្នាតតូច<br>- ថ្លៃចុះបញ្ជី<br>- ចំណាយសម្ភារៈផ្សេងៗ<br>- ថ្លៃជួសជុល<br>- តំណើរការអាជីវកម្ម |

| | | |
|---|---|---|
| | | - ចំណាយផ្សេងៗ 5% |
| ជម្រើសទី២៖ ចេញសេចក្តីព្រាងប្រកាសស្តីពី នីតិវិធីនិងលក្ខខណ្ឌក្នុងការផ្តល់អាជ្ញាបណ្ណធនធានរ៉ែសម្រាប់ការធ្វើអាជីវកម្មបូមខ្សាច់ទន្លេ ស្ទឹងព្រែក និងបឹងបួរ លក្ខណៈសិប្បកម្មនិងទ្រង់ទ្រាយតូចៗ | **ចំណាយសរុប 76 886,74 USD**<br>- ប្រជុំផ្ទៃក្នុងក្រសួងចំនួន ១០ លើក<br>- ចំណាយសម្រាប់ការចុះស្ទង់មតិរយៈពេល ៥ ថ្ងៃចំនួន ២ លើក<br>- វេទិការសាធារណៈរយៈពេល១ថ្ងៃចំនួន ៣ លើក<br>- សិក្ខាសាលាផ្សព្វផ្សាយសាធាណៈចំនួន ៣ លើក<br>- ក្រុមការងាររអធិការកិច្ច | **ចំណាយសរុបចំនួន 15 225 USD**<br>- ម៉ាស៊ីនខ្នាតតូច<br>- ថ្លៃចុះបញ្ជី<br>- ចំណាយសម្ភារៈផ្សេងៗ<br>- ថ្លៃជួសជុល<br>- តំណើរការអាជីវកម្ម<br>- មូលនិធិអភិវឌ្ឍន៍រ៉ែ<br>- មូលនិធិបណ្តុះបណ្តាល<br>- កម្រៃសេវាចំណូលរដ្ឋ<br>- ចំណាយផ្សេងៗ 5% |

### ៤.២. ការកំណត់ប្រភេទនៃផលចំណេញ

| ជម្រើស | ប្រភេទនៃផលចំណេញ |
|---|---|
| សំណើបញ្ញត្តិកម្ម៖ | |
| ជម្រើសទី១៖ រក្សាស្ថានភាពដើម និងពង្រឹងការអនុវត្តលិខិតបទដ្ឋានដែលមានស្រាប់ | -ជម្រើសទីមួយនេះជាជម្រើសដែលមានបន្ទុកចំណាយតិច និងមានផលចំណេញច្រើនដោយសារខ្លឹមសារនៃលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់ពិសេស ប្រកាសលេខ៣២១រថ.អធរ.ប្រក ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពី "ការធ្វើប្រតិភូកម្មមុខងារក្នុងការផ្តល់អាជ្ញាបណ្ណធនធានរ៉ែសម្រាប់ប្រតិបត្តិការរ៉ែមានលក្ខណៈជាសិប្បកម្មនិងខ្នាតតូចទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិរាជធានី ខេត្ត" មានលក្ខណៈគ្រប់គ្រាន់និងងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ រួមទាំងផ្តល់ផលចំណេញជាច្រើនទៀតរួមមាន៖<br>-កាត់បន្ថយការធ្វើអាជីវកម្មបូមខ្សាច់ខ្នាតតូចខុសច្បាប់<br>-លើកកំពស់ការប៉ះពាល់និងការខូចខាតបរិស្ថាន<br>-ប្រមូលចំណូលចូលរដ្ឋប្រសើជាងមុន<br>-កាត់បន្ថយការប៉ះពាល់ខុសភាពនិងអាយុជីវិតប្រជាពលរដ្ឋដែលនៅក្បែតំបន់ប្រតិបត្តិការធនធានរ៉ែ<br>-កាត់បន្ថយការធ្វើអាជីវកម្មខុសតំបន់អនុញ្ញាតនិងខុសស្តង់ដាបច្ចេកទេស |

| | |
|---|---|
| | -កាត់បន្ថយការបំពុលទឹក មនុស្ស សត្វនិងជីវៈចំរុះ<br>-មានភាពងាយស្រួលក្នុងការគ្រប់គ្រង់អាជីវកម្មនិងពន្ធ |
| ជម្រើសទី២៖ ចេញសេចក្តីប្រកាសស្តីពី នីតិវិធីនិងលក្ខខណ្ឌក្នុងការផ្តល់អាជ្ញាបណ្ណធនធានរ៉ែ សម្រាប់ការធ្វើអាជីវកម្មបូមខ្សាច់ទន្លេ ស្ទឹងព្រែក និងបបឹងបួរលក្ខណៈសិប្បកម្មនិងទ្រង់ទ្រាយតូច។ | ជម្រើសទីពីរមិនបានផ្តល់ផលចំណេញច្រើននោះទេ ប៉ុន្តែកាន់តែបង្កភាពស្មុគស្មាញដល់អាជីវករក្នុងការអនុវត្តទៀតផង ដោយសារតែខ្លឹមសារនៃសេចក្តីព្រាងប្រកាសនេះមានលក្ខណៈស្មុគស្មាញ និងយោងទៅលើលក្ខខណ្ឌនៃប្រកាសដែលនិរាករណ៍រួចហើយ។ |

## ៤.៣. វិសាលភាពនៃជម្រើសនីមួយៗ

| ជម្រើស | វិស័យឬប្រភេទធុរកិច្ច | ចំនួនធុរកិច្ច | ឯកសារយោង/ភស្តុតាង |
|---|---|---|---|
| ជម្រើសទី១៖ រក្សាស្ថានភាពដើម និងពង្រឹងការអនុវត្តលិខិតបទដ្ឋានដែលមានស្រាប់ | គ្របដណ្តប់លើការធ្វើអាជីវកម្មធនធានរ៉ែគ្រប់ប្រភេទដោយកំណត់ពីនីតិវិធី និងលក្ខខណ្ឌបច្ចេកទេសដែលមានលក្ខណៈសិប្បកម្មនិងទ្រង់ទ្រាយតូច (ដែលមានចែងក្នុងឧបសម្ព័ន្ធទៅតាមប្រភេទនីមួយៗ) | ១៧ | កិច្ចប្រជុំពិភាក្សាជាមួយក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តក្រសួងរ៉ែនិងថាមពល |
| ជម្រើសទី២៖ ចេញសេចក្តីព្រាងប្រកាស ស្តីពី នីតិវិធី និងលក្ខខណ្ឌក្នុងការផ្តល់អាជ្ញាបណ្ណធនធានរ៉ែ សម្រាប់ការធ្វើអាជីវ-កម្មបូមខ្សាច់ទន្លេ ស្ទឹងព្រែក និងបឹងបួរ លក្ខណៈសិប្បកម្មនិងទ្រង់ទ្រាយតូច | អាជីវកម្មបូមខ្សាច់ទន្លេ ស្ទឹង ព្រែក និងបឹងបួរលក្ខណៈសិប្បកម្មនិងទ្រង់ទ្រាយតូច។ | ១៧ | ការចុះស្ទង់មតិនៅខេត្តសៀមរាប និងខេត្តពោធិ៍សាត់ |

## ៥. កិច្ចពិគ្រោះយោបល់

ក្រោយបានធ្វើការស្ទង់មតិនៅខេត្តពោធិសាត់រួចហើយ អាជីវករបូមខ្សាច់ចំនួន៣០នាក់បានប្រាប់មកក្រុមការងារនូវបញ្ហាប្រឈមនៃការធ្វើអាជីវកម្មបូមខ្សាច់លក្ខណៈសិប្បកម្មនៅតាមផ្លូវទឹក និងបានលើកជាសំណូមពរដែលមានខ្លឹមសារដូចតទៅ៖ (បន្ថែមយោបល់អាជីវករ)

**១-បញ្ហាប្រឈម** (Other comment)

- អាជីវករមួយចំនួនសម្រេចចិត្តធ្វើអាជីវកម្មបូមយកខ្សាច់ទាំងគ្មានអាជ្ញាបណ្ណដើម្បីរកចំណូលសម្រាប់ទ្រទ្រង់ជីវភាព ប៉ុន្តែពួកគាត់យល់ព្រមក្នុងការបង់ប្រាក់សួយសារ ប្រាក់អត្ថប្រយោជន៍បន្ថែម និង

កម្រៃផ្សេងទៀតជូនរដ្ឋ។ ពួកគាត់បានលើកឡើងថា មូលហេតុនៃការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណនេះគឺដោយសារមានភាពយឺតយ៉ាវនៃការងាររដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការយល់ព្រមលើសំណើសុំអនុញ្ញាតផ្តល់ទីតាំងសម្រាប់ធ្វើប្រតិបត្តិការអាជីវកម្មសិប្បកម្មធនធានរ៉ែ។

- ប្រជាពលរដ្ឋដែលរស់នៅតាមច្រាំងទន្លេ ស្ទឹង បឹងបួរ និងព្រែកបានធ្វើការរំខានដល់អាជីវករដែលធ្វើការបូមខ្សាច់នៅតាមទន្លេ ស្ទឹង បឹងបួរ និងព្រែក ដោយលើកឡើងថាទីតាំងនៃការបូមខ្សាច់ដែលស្ថិតនៅតាមដងទន្លេ ស្ទឹង និងព្រែកទាំងនោះស្ថិតក្នុងដីកម្មសិទ្ធិរបស់គាត់។ លើសពីនេះទៅទៀត ពួកគាត់បានអះអាងថាការប្រឆាំងមិនឱ្យមានប្រតិបត្តិការធនធានរ៉ែនេះគឺការពារកុំឱ្យមានការបាក់ដីនៅតាមច្រាំង។
- ទីតាំងបូមខ្សាច់មួយចំនួនគ្មានខ្សាច់សម្រាប់បូម ហើយទីតាំងខ្លះទៀតអាចបូមបានត្រឹមតែប្រាំមួយខែប៉ុណ្ណោះ។

**២-សំណូមពរ** (Other comment)

- ជួយសម្រួលដល់ការផ្តល់អាជ្ញាបណ្ណឱ្យបានទាន់ពេលវេលា ដើម្បីឱ្យអាជីវករមានពេលវេលាគ្រប់គ្រាន់សម្រាប់ស្វែងរកចំណូលទ្រទ្រង់ជីវិត។
- ធ្វើការពន្យល់ណែនាំដល់ប្រជាពលរដ្ឋដែលរស់នៅតាមដងទន្លេ ស្ទឹង បឹងបួរ និងព្រែកអំពីសិទ្ធិកាន់កាប់ដីធ្លីរបស់ពួកគាត់
- បន្ថយអត្រាកម្រៃសួយសារ អត្ថប្រយោជន៍បន្ថែម និងកម្រៃសេវាផ្សេងទៀត

## ៦. សន្និដ្ឋាន

តាមការសន្និដ្ឋានយើងសង្កេតឃើញថា "ជម្រើសទី១" ជាជម្រើសដ៏ស័ក្តសមបំផុតសម្រាប់ដោះស្រាយបន្ទុកក្នុងការគ្រប់គ្រងរបស់ក្រសួងរ៉ែនិងថាមពល និងសម្រួលដល់ធុរៈកិច្ចក្នុងការអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

"ជម្រើស២" មិនបានផ្តល់ផលចំណេញណាមួយដែលគួរឲ្យកត់សម្គាល់នោះទេ។ ជម្រើសទី២ តម្រូវឱ្យមានការប្រើប្រាស់ថវិការរដ្ឋបន្ថែមច្រើន និងបង្កឱ្យមានភាពស្មុគស្មាញចំពោះអាជីវករនៅពេលអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តផងដែរ ដោយសារខ្លឹមសារនៃប្រកាសនេះមានភាពប្រហាក់ប្រហែលទៅនឹងប្រកាសលេខ៣២១រថ.អធរ.ប្រក ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពី "ការធ្វើប្រតិភូកម្មមុខងារក្នុងការផ្តល់អាជ្ញាបណ្ណធនធានរ៉ែសម្រាប់ប្រតិបត្តិការរ៉ែមានលក្ខណៈជាសិប្បកម្មនិងខ្នាតតូចទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិរាជធានី ខេត្ត"។

ការធ្វើអាជីវកម្មបូមខ្សាច់ទន្លេ ស្ទឹង ព្រែក និងបឹងបួរនេះមិនមានផលប៉ះពាល់គួរឲ្យកត់សម្គាល់ចំពោះធុរកិច្ចទេ ដូច្នេះប្រកាសនេះមិនគួរត្រូវវាយតម្លៃពេញលេញបន្តទៀតទេ។

**តើចាំបាច់ធ្វើ RISដែរឬទេ?**

☐ ចាំបាច់៖

☑ មិនចាំបាច់៖

ដោយសារតែជម្រើសទី១មានលក្ខណៈជាសិប្បកម្មនិងទ្រង់ទ្រាយខ្នាតតូច ដែលមិនបង្កឲ្យមានផលប៉ះពាល់ជាអវិជ្ជមានធ្ងន់ធ្ងរ ឬគួឲ្យគាត់សម្គល់នោះទេ (បន្ទុកចំណាយទាប...)។

## ៧. ការអនុវត្ត និងការតាមដានត្រួតពិនិត្យ

### ៧.១. ដើម្បីលើកកម្ពស់តម្លាភាព និងអភិបាលកិច្ចល្អក្នុងអំឡុងពេលនៃការដាក់ឲ្យអនុវត្ត

អគ្គនាយកដ្ឋានជំនាញនៃក្រសួងរ៉ែនិងថាមពលគួរធ្វើការផ្សព្វផ្សាយប្រកាសលេខ ៣២១រថ.អធរ.ប្រក ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពី "ការធ្វើប្រតិភូកម្មមុខងារក្នុងការផ្តល់អាជ្ញាបណ្ណធនធានរ៉ែសម្រាប់ប្រតិបត្តិការរ៉ែមានលក្ខណៈជាសិប្បកម្មនិងខ្នាតតូចទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិរាជធានី ខេត្ត" នេះឲ្យបានទូលំទូលាយដល់សាធារណៈជន អាជីវករ និងអ្នកពាក់ព័ន្ធ និងណែនាំទៅមន្ទីររ៉ែនិងថាមពល រាជធានីខេត្ត ចុះផ្សព្វផ្សាយដល់មូលដ្ឋាន និងពង្រឹងសមត្ថិភាពមន្ត្រីថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិក្នុងការចុះត្រួតពិនិត្យ និងធ្វើអធិការកិច្ចលើលក្ខណៈបច្ចេកទេសក្នុងការធ្វើប្រតិបត្តិការបូមយកខ្សាច់។

### ៧.២. ការត្រួតពិនិត្យនិងតាមដាន

(ប្រកាសលេខ ៣២១ កំណត់ពេល)

| ដំណើរការ | ឈ្មោះ | មុខងារ | ទំនាក់ទំនង |
|---|---|---|---|
| រៀបចំដោយក្រសួងរ៉ែនិងថាមពល | យ៉ែម កាន់នីកា | អគ្គនាយករង នៃអគ្គនាយកដ្ឋានកិច្ចការទូទៅ | ០១២ ៨៥០ ៨៥៦ |
| | សួរ ប៊ុនម៉ារីយ៉ា | អនុប្រធាននាយកដ្ឋាននីតិកម្ម | ០១៦ ៣៨១ ៤៣៨ |
| | សូ រចនា | អនុប្រធានការិយាល័យស្រាវជ្រាវ និងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត | ០១២ ៣២៣ ៤៣៦ |
| | | | |
| ផ្តល់យោបល់ដោយ ECOSOCC/RET | ឯកឧត្តម ប៊ិច សុខា | អនុប្រធានRET | ០១២ ៦៩៨ ៩៩៩ |
| | ឯកឧត្តម អេង រត្នមុនី | ប្រធានផ្នែកបណ្តុះបណ្តាល | ០១២ ៩១២ ០០៩ |
| | | | |
| ជំនួយការ | លោក រ៉ុម ផល្លីស | បុគ្គលិករដ្ឋបាល | ០៧៨ ២៣៥ ០៧៨ |